Industry

# ជំងឺប៉េស្តជ្រូកអាហ្រ្វិក



**ជំងឺប៉េស្តជ្រូកអាហ្រ្វិក (ASF) គឺជាជំងឺសត្វជ្រូកដែលឆ្លងខ្លាំងបំផុត ហើយឆ្លងរាលដាលយ៉ាងឆាប់រហ័សនៅអឺរ៉ុបខាងកើត ប្រទេសចិន និងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍។**

ការផ្ទុះជំងឺប៉េស្តជ្រូកអាហ្រ្វិកនៅអូស្ត្រាលីអាចនឹងមានផលអវិជ្ជមានធ្ងន់ធ្ងរដល់សុខភាពរបស់សត្វជ្រូក ការផលិតសាច់ជ្រូក និងធ្វើឲ្យមហន្តរាយដល់ឧស្សាហកម្មសាច់ជ្រូក ប្រសិនបើជំងឺនេះចូលវាយលុក។

ជំងឺនេះឆ្លងរាលដាលតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយសត្វជ្រូកមានជំងឺ រថយន្តឬសម្ភារៈដឹកជញ្ជូនសត្វ មានជំងឺ ឬតាមរយៈសំលៀកបំពាក់ និងតាមរយៈការឲ្យចំណីដែលមានលាយឡំជាមួយផលិតផលសត្វ ឬសំណល់សាច់ដែលអាចមានមេរោគដល់សត្វជ្រូក។

ជំងឺនេះគ្មានថ្នាំវ៉ាក់សាំងការពារ ឬថ្នាំព្យាបាលទេ។ ដូចនេះការការពារមិនឲ្យជំងឺនេះ (ASF)
មកប្រទេសអូស្ត្រាលី មានសារៈសំខាន់ណាស់ ហើយយើងត្រូវការការរួមចំណែកពីអ្នក។

## ការអនុវត្តភូមិគាមអនាម័យឲ្យបានល្អ និងការរក្សាអនាម័យមានសារៈសំខាន់ណាស់

- ជំងឺប៉េស្តជ្រូកអាហ្រ្វិកអាចជាប់មកជាមួយមនុស្សតាមស្បែក សំលៀកបំពាក់ ស្បែកជើង និងនៅលើសក់។ នៅពេលអ្នក ឬកម្មកររបស់អ្នកចូលក្នុងកសិដ្ឋាន ឬកន្លែងផលិតកម្ម ចូរធានាថាអ្នកប្រើប្រាស់ ៖
  - ឧបករណ៍ដែលមាននៅកន្លែងផលិត ស្បែកជើងកវែង និងសម្ភារៈផ្សេងៗប្រសិនបើផ្តល់ជូន
  - ធុងទឹកសម្រាប់លាងស្បែកជើង
  - ថ្នាំសម្លាប់មេរោគសមស្របដូចជា ក្លរ ឬ Virkon S ដើម្បីសម្អាតសម្ភារៈ
- ពេលអ្នក ឬកម្មកររបស់អ្នកចាកចេញពីកសិដ្ឋាន ឬកន្លែងផលិត ចូរបាញ់ថ្នាំសម្លាប់មេរោគលើស្បែកជើង សំលៀកបំពាក់ រថយន្ត និងសម្ភារៈផ្សេងៗដែលចេញពីទីតាំងនោះ។
- ចូរកុំភ្លេចលាងដៃនឹងសាប៊ូជាមួយទឹក មុន និងក្រោយពេលចាត់ចែងសត្វ។

## ការត្រួតពិនិត្យតាមដានកម្មករមកពីប្រទេសក្រៅ

- សម្រាប់កម្មករទាំងឡាយណាដែលបានប៉ះពាល់ជាមួយសត្វជ្រូកនៅប្រទេសរបស់ខ្លួន គួររង់ចាំប្រាំពីរថ្ងៃមុនពេលប៉ះពាល់សត្វជ្រូកនៅអូស្ត្រាលី ឬចៀសវាងកុំប៉ះពាល់សត្វជ្រូកឲ្យសោះ។
- កម្មករមិនត្រូវយកសំលៀកបំពាក់ ឬសម្ភារៈផ្សេងៗដែលប្រើប្រាស់ពេលមើលថែ/ប៉ះពាល់ជ្រូកនៅប្រទេសរបស់ខ្លួនមកកាន់ប្រទេសអូស្ត្រាលីឡើយ។

## ការដឹងពីរោគសញ្ញា

ការដឹងពីរោគសញ្ញាដំបូងមានសារៈសំខាន់ណាស់ក្នុងការលុបបំបាត់ជំងឺ។ រោគសញ្ញាដែលបង្កដោយជំងឺ ASF រួមមាន ៖

- ជ្រូកងាប់ភ្លាមៗ ឬងាប់ក្នុងរយៈពេល មួយ ឬពីរថ្ងៃ
- ស្បែកឡើងកន្ទួលក្រហម ជាពិសេសនៅត្រចៀក
- ជ្រូកមិនស៊ីចំណី
- ជ្រូកនៅជុំៗគ្នា ឬលាក់ខ្លួននៅកន្លែងកៀនកាច់ជ្រុង
- មានជំងឺរាក ដែលអាចមានលាយឈាម

## ចូរការពារកសិដ្ឋានរបស់អ្នក

ចូរមើលឯកសារផ្សេងៗដើម្បីរក្សាកសិដ្ឋានរបស់អ្នកឲ្យបានស្អាតនៅលើគេហទំព័រភូមិគាមអនាម័យកសិដ្ឋានដែលមានអាសយដ្ឋាន៖ farmbiosecurity.com.au

**ប្រសិនបើមានអ្វីគួរឲ្យសង្ស័យ សូមទូរស័ព្ទទៅកាន់លេខ 1800 798 636.**

NORTHERN TERRITORY GOVERNMENT